**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ចំណុះក្រសួងមហាផ្ទៃ

***********

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត ០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បានឃើញ អនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

<u>មាត្រា ១</u> .-

ត្រូវបានបង្កើតនាយកដ្ឋានរដ្ឋបាលមូលដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ។

<u>មាត្រា ២</u> . -

នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវបំពេញកិច្ចការនានា ដែលទាក់ទងនឹងឃុំ សង្កាត់ និង នយោបាយវិមជ្ឈការ ។

- ក្នុងរយៈពេល នៃអាណត្តិរបស់គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ដែលបានបង្កើតឡើង ដោយព្រះរាជក្រឹត្យលេខ នស/រកត ០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ នាយកដ្ឋានរដ្ឋបាលមូលដ្ឋានមានតួនាទីជា លេខាធិការដ្ឋាន របស់គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ។

<u>មាត្រា ៣</u> . -

នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង អនុប្រធាន នាយកដ្ឋានមួយចំនួនជាជំនួយ ។

<u>មាត្រា ៤</u> . -

តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធរបស់ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ត្រូវកំណត់ដោយ ប្រកាស របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

<u>មាត្រា ៥</u> . -

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>មាត្រា ៦</u> . -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ភ្នំពេញ , ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*<u>កន្លែងទទួល</u>*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា ៦*

*-ឯកសារ-កាលប្បវត្តិ*